# សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត

# The Electoral Reform Alliance (ERA)

ភ្នំពេញថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៤

## សេចក្ដីជូនដំណឹង

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (Election Reform Alliance) ដែលចងក្រងដោយអង្គការសង្គមស៊ីវិល ដែលមានសមាជិកចំនួន២០ស្ថាប័ន មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក លោកស្រី នាងកញ្ញា ជាតំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ និងអន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបថា សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត នឹងរៀបចំសិក្ខាសាលាបង្ហាញអំពី "**សេចក្ដីស្នើវិសោធនកម្មក្របខណ្ឌច្បាប់ទាក់ទងស្ថាប័នគ្រប់គ្រងការបោះឆ្នោត យន្តការដោះស្រាយវិវាទបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត និងប្រព័ន្ធផ្សព្វផ្សាយក្នុងអំឡុងពេលបោះឆ្នោត**"។

សិក្ខាសាលាបង្ហាញនេះ ក៏នឹងមានការថ្លែងសន្ទរកថា និងមតិបើកសិក្ខាសាលាដោយ លោក **សុរិយា ប្រាសាទ ស៊ូប៊ែឌី** អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក **ធន សារ៉ាយ** ប្រធានសមាគមអាដហុក និងការថ្លែងសុន្ទរកថាបិទកម្មវិធីដោយលោកស្រី **ធីតា ឃឹះ** នាយិការអង្គការសីលការ និងជាប្រធានគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ចូលរួមផងដែរ។

អាស្រ័យដូចបានជម្រាបជូនដូចខាងលើ សេចក្ដីជូនដំណឹងនេះចាត់ទុកជាការគោរពអញ្ជើញ និងចូលរួមយកព័ត៌មានតាមការគួរ។

**គោលបំណង** ៖

១. បង្ហាញជូនភាគីពាក់ព័ន្ធអំពីសេចក្ដីស្នើវិសោធនកម្មក្របខ័ណ្ឌច្បាប់ទាំងនោះ។

២. ពិភាក្សាជាមួយភាគីពាក់ពាក់ព័ន្ធអំពីសេចក្ដីស្នើវិសោធនកម្មក្របខ័ណ្ឌច្បាប់ទាំងនោះ។

**កាលបរិច្ឆេទ** ៖ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤ (រយៈពេលមួយថ្ងៃ)

**ទីកន្លែង** ៖ សណ្ឋាគារហ៊ីម៉ាវ៉ារិ, រាជធានីភ្នំពេញ

សម្រាប់ព័ត៌មានបន្ថែម៖

លោក **សួន យុធា** (មន្ត្រីច្បាប់ និងតស៊ូមតិ ខុមហ្វ្រែល)

ទូរស័ព្ទ៖ ០៨៨ ៨១៤ ២៧ ៨៣